# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋផ្ទៃដីទំហំ ១៥០៨ ហិកតាមានទីតាំងនៅក្នុងឃុំកំពង់ដំរី ស្រុកឆ្លូង ខេត្តក្រចេះ សម្រាប់ធ្វើសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រស៊ីឈ្នួលនៅ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពី គោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់ និតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនិតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់និតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ចេញពីផែនទីគម្របព្រៃឈើឆ្នាំ ២០០២ ផ្ទៃដីទំហំ ៦៨៤ (ប្រាំមួយរយប៉ែតសិបបួន) ហិកតា ស្ថិតនៅក្នុងឃុំកំពង់ដំរី ស្រុកឆ្លូង ខេត្តក្រចេះ និងធ្វើអនុបយោគផ្ទៃដីនេះដែលជាដីសាធារណៈរបស់រដ្ឋ មកជាដីឯកជនរបស់រដ្ឋ ដូចមានបង្ហាញក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ដោយកំណត់តាមចំណុចគោលដែលមាននិយាមកានៃប្រព័ន្ធកូអរដោនេ UTM Zone 48 N, Datum: WGS 1984 ដូចខាងក្រោម៖

| ចំណុច | X | Y | ចំណុច | X | Y |
|---|---|---|---|---|---|
| 1 | 623579 | 1334319 | 6 | 623011 | 1333659 |
| 2 | 623578 | 1337636 | 7 | 626341 | 1333668 |
| 3 | 622522 | 1337632 | 8 | 626433 | 1334007 |
| 4 | 622508 | 1337440 | 9 | 626433 | 1334320 |
| 5 | 621917 | 1335175 | | | |

**មាត្រា ២.-**

ត្រូវបានកាត់ចេញពីសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ច័ន្ទ សុភា អភិវឌ្ឍន៍ ផ្ទៃដីទំហំ ៨២៤ (ប្រាំបីរយម្ភៃបួន) ហិកតា ស្ថិតនៅក្នុងឃុំកំពង់ដំរី ស្រុកឆ្លូង ខេត្តក្រចេះ ដូចមានបង្ហាញក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ដោយកំណត់តាមចំណុចគោលដែលមាននិយាមកានៃប្រព័ន្ធកូអរដោនេ UTM Zone 48 N, Datum: WGS 1984 ដូចខាងក្រោម៖

| ចំណុច | X | Y | ចំណុច | X | Y |
|---|---|---|---|---|---|
| 1 | 623579 | 1334319 | 15 | 626360 | 1336387 |
| 9 | 626433 | 1334320 | 16 | 626092 | 1336572 |
| 10 | 626461 | 1334842 | 17 | 625446 | 1336868 |
| 11 | 626583 | 1335049 | 18 | 624981 | 1337153 |
| 12 | 626412 | 1335587 | 19 | 624790 | 1337447 |
| 13 | 626510 | 1335929 | 20 | 624182 | 1337706 |
| 14 | 626534 | 1336247 | 2 | 623578 | 1337636 |

**មាត្រា ៣.~**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋដូចមានក្នុងមាត្រា ១ និងមាត្រា ២ ខាងលើនេះសរុបផ្ទៃដីទំហំ ១៥០៨ (មួយពាន់ប្រាំរយប្រាំបី) ហិកតា ជូនអភិបាលនៃគណៈអភិបាលខេត្តក្រចេះជាអាជ្ញាធរកាន់កាប់ដីរដ្ឋ ដើម្បីស្នើសុំចុះបញ្ជីជាដីឯកជនរបស់រដ្ឋ និងធ្វើសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រគ្មានដី និងខ្វះដី។

**មាត្រា ៤.~**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៥.~**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋាន គសសជ
-គ្រប់សមាជិក គសសជ
-ដូចមាត្រា ៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

## ផែនទីបង្ហាញទីតាំងសម្បទានដីសង្គមកិច្ចនៅឃុំកំពង់ដំរី ស្រុកឆ្លូង ខេត្តក្រចេះ ទំហំ ១៥០៨ (មួយពាន់ ប្រាំរយប្រាំបី) ហិកតា

ឧបសម្ព័ន្ធអនុក្រឹត្យលេខៈ ៥៨. អនក្រ.បក ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០១២




| ចំណុច | Easting (X) | Northing (Y) | ចំណុច | Easting (X) | Northing (Y) |
|---|---|---|---|---|---|
| 1 | 623579 | 1334319 | 11 | 626583 | 1335049 |
| 2 | 623578 | 1337636 | 12 | 626412 | 1335587 |
| 3 | 622522 | 1337632 | 13 | 626510 | 1335929 |
| 4 | 622508 | 1337440 | 14 | 626534 | 1336247 |
| 5 | 621917 | 1335175 | 15 | 626360 | 1336387 |
| 6 | 623011 | 1333659 | 16 | 626092 | 1336572 |
| 7 | 626341 | 1333668 | 17 | 625446 | 1336868 |
| 8 | 626433 | 1334007 | 18 | 624981 | 1337153 |
| 9 | 626433 | 1334320 | 19 | 624790 | 1337447 |
| 10 | 626461 | 1334842 | 20 | 624182 | 1337706 |

**Coordinate System**

Projection: Universal Transverse Mercator

Datum: WGS1984

Zone: 48N

0 1,000 2,000 Meters

ទីតាំងសម្បទានដីសង្គមកិច្ច